# ហេរិញ្ញវត្ថុនៃទីក្រុងឡុងប៊ិច

**ការលក់ដេញថ្លៃប្រាតិភោគបំណុល**

ការលក់ដេញថ្លៃប្រាតិភោគបំណុលនៅទីក្រុងឡុងប៊ិច ត្រូវបានរៀបចំឡើង នៅថ្ងៃអង្គារ៍ជារៀងរាល់ពីរសប្តាហ៍ម្តង និងបើកទូលាយឱ្យសាធារណៈជនចូលរួម ដែលមានទីតាំងស្ថិតនៅអគារ 3111 E ផ្លូវ Wilow ទីក្រុងឡុងប៊ិច រដ្ឋកាលីហ្វ័រញ៉ា  ចន្លោះផ្លូវ Temple និងផ្លូវ Redondo។ រថយន្តទាំងអស់ ត្រូវដាក់លក់ “តាមស្ថានភាពជាក់ស្តែង” ជាមួយនឹងរាល់បញ្ហាទាំងអស់ត្រូវបានបង្ហាញ។ អ្នកលក់មិនធានា និងមិនបង្វិលសងប្រាក់វិញឡើយ។ រថយន្តត្រូវដាក់
លក់ក្នុងការលក់ដេញថ្លៃប្រកួតប្រជែងជាលក្ខណៈបើកចំហ។
អ្នកដេញថ្លៃដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេនឹងទទួលបានរថយន្តនោះ។ អ្នកដាក់ដេញថ្លៃរក្សាសិទ្ធិបដិសេធរាល់ការដេញថ្លៃ ឬ បញ្ឈប់ការលក់រថយន្ត។ ក្នុងករណីមានជម្លោះ ការសម្រេចរបស់អ្នកដាក់ដេញថ្លៃ គឺជាសេចក្តីសម្រេចចុងក្រោយ។

**បញ្ជី និងរូបថតសម្រាប់ការដេញថ្លៃ**

ដើម្បីមើលបញ្ជី ឬ រូបថត សូមចុចលើចំណងជើងសមស្របខាងក្រោម។ ឯកសារអាចព្រីន និង/ឬ រក្សាទុក។ បើសិនចុចហើយ មិនឃើញមានឯកសារទេនោះ មានន័យថា
វាមិនទាន់អាចរកបាននៅឡើយទេ។

**សេចក្តីលម្អិតនៃការដេញថ្លៃ**

- អ្នកដេញថ្លៃត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើង និងមានអាជ្ញាប័ណ្ណបើកបរមានសុពលភាព ឬ អត្តសញ្ញាណប័ណ្ណរដ្ឋមានសុពលភាព ដែលមានថ្ងៃខែឆ្នាំកំណើត។
- មិនអនុញ្ញាតឱ្យនាំឆ្កែទៅជាមួយ (លើកលែងឆ្កែនាំផ្លូវ)
- មិនត្រូវពាក់ស្បែកជើងសង្រែក ឬ ស្បែកជើងដែលលេចចេញម្រាមជើង។
- **ឥឡូវនេះ ការចូលរួម និងការចូលមើល និងការចូលរួមដេញថ្លៃ គឺមិនត្រូវបានគិតថ្លៃឡើយ។**
- អ្នកចូលរួមទាំងអស់តម្រូវឱ្យចុះឈ្មោះចូលរួមក្នុងដំណើរការនៃការដេញថ្លៃ។ អ្នកដេញថ្លៃដែលឈ្នះនឹងត្រូវបង់ប្រាក់ $21 សម្រាប់ថ្លៃសេវាដេញថ្លៃ។ ថ្លៃសេវានេះ មិនពាក់ព័ន្ធនឹង
តម្លៃដេញថ្លៃទិញរថយន្តឡើយ។
- មិនអនុញ្ញាតឱ្យចូលរួមក្រោយម៉ោង 9:50 a.m.
- ទម្រង់នៃការទូទាត់ប្រាក់៖ សាច់ប្រាក់, Visa, MasterCard, Discover Card, ឬ ប័ណ្ណឥណពន្ធពីសហរដ្ឋអាមេរិក (មិនទទួលមូលប្បទានប័ត្រឡើយ)។ សាច់ប្រាក់
គឺសម្រាប់តែការចុះឈ្មោះប័ណ្ណអ្នកដេញថ្លៃប៉ុណ្ណោះ។
- **រថយន្តដែលបានទិញ ត្រូវទូទាត់ប្រាក់ត្រឹមម៉ោង 4:00 p.m នៅថ្ងៃលក់។**
- រថយន្តដែលបានទិញ ត្រូវយកចេញពីបរិវេណទីក្រុង ដោយរថយន្តសណ្តោងត្រឹមម៉ោង 5:30 p.m. នៅថ្ងៃលក់។
- **រថយន្តដែលមានសោ នឹងត្រូវវាយតម្លៃ
ដើម្បីដកថ្លៃកូនសោស្រគួរក្នុងចំណាយចុងក្រោយនៃការទិញរថយន្តនីមួយៗ។
សូមមើលទំព័រថ្លៃរថយន្តសណ្តោង សម្រាប់ព័ត៌មានលម្អិតអំពីថ្លៃសេវា។**
- ទ្រព្យសម្បត្តិនៅក្នុងរថយន្តគឺជាកម្មសិទ្ធិរបស់ទីក្រុងឡុងប៊ិច។
ជនណាដែលយកទ្រព្យសម្បត្តិពីរថយន្ត នឹងត្រូវស្វែងរកមុខ និងកាត់ទោស។

# ហិរញ្ញវត្ថុនៃទីក្រុងឡុងប៊ិច

- ទីក្រុងឡុងប៊ិចហាមឃាត់ការថតវីដេអូ ឬ រូបថត ខណៈពេលនៅក្នុងបរិវេណនេះ លុះត្រាតែមានការអនុញ្ញាតជាពិសេសពីគណៈគ្រប់គ្រងទីក្រុងឡុងប៊ិច។

| | |
|---|---|
| ច្រកផ្លូវបើក | ម៉ោង 8:00 am - 9:50 am |
| ម៉ោងត្រួតពិនិត្យរថយន្ត | ម៉ោង 8:00 am - 9:50 am |
| ម៉ោងចុះឈ្មោះដេញថ្លៃ | ម៉ោង 8:00 am - 9:50 am |
| ការដេញថ្លៃចាប់ផ្ដើម | ម៉ោង 9:50 am |

**សម្រាប់ព័ត៌មានបន្ថែម ៖**

- ទូរស័ព្ទ (562) 570-2828
- Para ayuda en espanol oprima el numero (562) 570-2828; ឬ
- ទៅកាន់ការិយាល័យផ្នែកការលក់ប្រាតិភោគបំណុល និងការសណ្ដោង នៃទីក្រុងឡុងប៊ិច អគារ 3111 E. Willow Street, Long Beach, CA

**ការលក់ប្រាតិភោគបំណុល និងការសណ្ដោង**

**562-570-2828**

FM-Towing@LongBeach.Gov

- ទំព័រដើមការលក់ប្រាតិភោគបំណុល និងការសណ្ដោង
- ការដេញថ្លៃ
- ការទៅយករថយន្តរបស់អ្នក
- ថ្លៃសេវាសណ្ដោង
- ព័ត៌មានស្ដីពីការទូទាត់
- ព័ត៌មានស្ដីពីការបញ្ចេញ
- អត្តសញ្ញាណទទួលយកបាន
- ការទាមទារទ្រព្យសម្បត្តិ
- ការបញ្ចេញរថយន្តទៅឱ្យតតិយភាគី